# ការអនុវត្តជាក់ស្តែងនៃការលៃងលៈ I

ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
សាស្ត្រាចារ្យ Higashio Kazuyuki
2018.3.15

# មូលហេតុនៃការលែងលះគ្នា

# មូលហេតុនៃការលែងលះគ្នា

អាចដាក់ពាក្យបណ្តឹងលែងលះគ្នាបាន តែក្នុងករណីដែលចំណុចណាមួយក្នុងចំណុចទាំង៥ខាងក្រោមនេះ ត្រូវបានទទួលស្គាល់តែប៉ុណ្ណោះ (ក្រមរដ្ឋប្បវេណីមាត្រា៩៧៨ កថាខណ្ឌទី១)។

1. អំពើផិត(ចំណុច ក)
2. បោះបង់សហព័ន្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ(ចំណុច ខ)
3. មិនដឹងស្លាប់ ឬ រស់ អស់រយៈពេលជាង១ឆ្នាំ(ចំណុច គ)
4. រស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំ(ចំណុច ឃ)
5. ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន(ចំណុច ង)

# មូលហេតុនៃការលែងលះគ្នា

1. អំពើផិត(ក្រមរដ្ឋប្បវេណីមាត្រា៩៧៨ កថាខណ្ឌទី១ ចំណុច ក)

2. បោះបង់សហព័ន្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ (ក្រមរដ្ឋប្បវេណីមាត្រា៩៧៨ កថាខណ្ឌទី១ ចំណុច ខ)

បោះបង់ចោល = ការបោះបង់ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក (ក្រមរដ្ឋប្បវេណីមាត្រា ៩៦៦)

3. មិនដឹងស្លាប់ ឬ រស់ អស់រយៈពេលជាង១ឆ្នាំ (ក្រមរដ្ឋប្បវេណីមាត្រា៩៧៨ កថាខណ្ឌទី១ ចំណុច គ)

ភាពសត្យានុម័តនៃស្ថានភាពដែលមិនដឹងស្លាប់ ឬ រស់ គឺបានបន្តរយៈពេល១ឆ្នាំ។ ត្រឹមតែជាការបាត់ខ្លួន ឬ ការមិនអាចទាក់ទងបាន គឺមិនគ្រប់គ្រាន់ទេ។ ត្រូវតែស្ថិតក្នុងកម្រិតដែលស្មើនឹងលទ្ធភាពនៃការស្លាប់។

# មូលហេតុនៃការលែងលះគ្នា

4. រស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង១ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ (ក្រមរដ្ឋប្បវេណីមាត្រា៩៧៨ កថាខណ្ឌទី១ ចំណុច ឃ)

ជាចំណុចដែលយកអំឡុងពេលជាក់លាក់នៃការរស់នៅបែកគ្នាដែលជាចំណុចសត្យានុម័ត មកធ្វើជាមូលហេតុនៃការលែងលះគ្នា។ ចំណុចនេះ ងាយស្រួលក្នុងការបញ្ជាក់ និង សម្រេចសេចក្តីជាង“ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់” (មាត្រាដដែល ចំណុច ង )។កម្រិតដែលធ្វើឲ្យភាពឯកជនរវាងប្តីប្រពន្ធមានភាពច្បាស់លាស់ក៏នឹងមានការធ្លាក់ចុះដែរ។

ការរស់នៅបែកគ្នាដោយសារទៅធ្វើការនៅឆ្ងាយតែម្នាក់ឯងដោយទុកគ្រួសារចោល មិនក្លាយជាការ “ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍” ទេ ។

# មូលហេតុនៃការលែងលះគ្នា

5. ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញបាន( ក្រមរដ្ឋប្បវេណី មាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច ង )

ជាចំណុចដែលបញ្ញត្តដោយសរុបទាំងអស់ចំពោះករណីដែលមិនត្រូវនឹងលក្ខខណ្ឌខាងលើចាប់ពី១~៤។

ក្នុងករណីដែលធាតុណាមួយខាងក្រោមនេះត្រូវបានទទួលស្គាល់ នឹងចាត់ទុកថា នឹងមិនមាននូវទំនាក់ទំនងក្នុងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញ៖

- ប្តីប្រពន្ធទាំងសងខាងគ្មានឆន្ទៈបន្តអាពាហ៍ពិពាហ៍( ធាតុអត្តនោម័ត )
- មានភាពលំបាកយ៉ាងខ្លាំងក្នុងការស្តារជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ ( ធាតុសត្យានុម័ត )

# មូលហេតុនៃការលែងលះគ្នា

ដោយសារជាលក្ខខណ្ឌដែលមានភាពអរូបិយ ដូចនេះ មិនអាចបញ្ជាក់ដោយផ្ទាល់អំពី “មិនមានឆន្ទះបន្តអាពាហ៍ពិពាហ៍” និង “មានភាពលំបាកយ៉ាងខ្លាំងក្នុងការស្តារជីវភាពរួមក្នុងអាពាហ៍ពិពាហ៍” ជាអាទិ៍បានទេ។ ហេតុនេះ យើងត្រូវអះអាងបញ្ជាក់ភស្តុតាងអំពីអង្គហេតុជាក់ស្តែង ដែលអាចវាយតម្លៃថាជាហេតុដែលត្រូវនឹងស្ថានភាពខាងលើ។

(ឧទាហរណ៍)

អំពើហិង្សា

បទល្មើស ឬ ការទទួលពិន័យ

ចាយវាយប្រាក់ខ្ជះខ្ជាយយ៉ាងខ្លាំង

# មូលហេតុនៃការលែងលះគ្នា

ដូចដែលបានលើកឡើងខាងលើ នៅក្នុងក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា ការបែកបាក់ទំនាក់ទំនងអាពាហ៍ពិពាហ៍ដែលមានភាពសត្យានុម័ត ត្រូវបានដាក់ចូលជាមូលហេតុនៃការលែងលះគ្នា។ ស្ថានភាពដែលភាគីម្ខាងទៀតមានការទទួលខុសត្រូវទៅលើអ្វីមួយ ជាគោលការណ៍គឺមិនទាក់ទងទៅនឹងការសម្រេចសេចក្ដីអំពីមូលហេតុនៃការលែងលះគ្នា។

ប៉ុន្តែ បើសិនជាទទួលស្គាល់ការលែងលះតែតាមរយៈធាតុសត្យានុម័ត នឹងមានការបារម្ភថាមានលទ្ធផលដែលមានភាពមិនស្របគ្នា។ បើសិនជាមានភាពជាក់លាក់ដូចលើកឡើងក្នុងចំណុចបន្ទាប់ ទោះបីជាមូលហេតុនៃការលែងលះគ្នាត្រូវបានទទួលស្គាល់ក៏ដោយ ក៏តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះ ដោយឆន្ទានុសិទ្ធិបាន។

# ការប្រានចោលការទាមទារដោយឆន្ទានុសិទ្ធិ

- ទោះបីជាមានមូលហេតុនៃការលែងលះគ្នាក៏ដោយ ប្រសិនបើយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្តាលឲ្យការទ្រទ្រង់ជីវភាពរបស់សហព័ន្ធ ឬ កូន ក្រលំបាកយ៉ាងខ្លាំង ឬ មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការអាចប្រានចោលការទាមទារលែងលះគ្នាបាន (ក្រមរដ្ឋប្បវេណីមាត្រា៩៧៨ កថាខណ្ឌទី២)។

ជាចំណុចដែលគិតពិចារណាដល់សុខុមាលភាពរបស់សហព័ន្ធ ឬ កូន។ បើសិនជាលទ្ធផលនឹងធ្វើឲ្យសហព័ន្ធ ឬ កូនមានភាពតឹងរ៉ឹងខ្លាំងពេក តុលាការអាចប្រានចោលការទាមទារលែងលះគ្នាបាន។

# ការច្រានចោលការទាមទារដោយឆន្ទានុសិទ្ធិ

- នៅក្នុងករណីនៃចំណុច ឃ ឬ ចំណុច ង ខាងលើ ប្រសិនបើយល់ឃើញថាការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារឲ្យលែងលះគ្នានោះ ធ្វេសប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិ និង ជួយសង្គ្រោះចំពោះសហព័ន្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះ ដោយឆន្ទានុសិទ្ធិបាន (ក្រមរដ្ឋប្បវេណីមាត្រា ៩៧៨ កថាខណ្ឌទី៣)។

ការទាមទារឲ្យលែងលះគ្នាដោយសហព័ន្ធដែលបានបង្កើតនូវមូលហេតុអំពីការបែកបាក់ដែលផ្ទុយនឹងភាពសុចរិត តុលាការអាចនឹងមិនទទួលស្គាល់នូវការទាមទារនោះបាន។

# ការបែកចែកទ្រព្យសម្បត្តិ

# ការបែងចែកទ្រព្យសម្បត្តិ

- នៅពេលលែងលះគ្នា ប្តីប្រពន្ធចាំបាច់ត្រូវតែពិភាក្សាគ្នាអំពីការបែងចែកទ្រព្យសម្បត្តិ(ក្រមរដ្ឋប្បវេណីមាត្រា ៩៨០ កថាខណ្ឌទី១)។ក្នុងករណីដែលមិនអាចពិភាក្សាគ្នាបាន នឹងសម្រេចដោយផ្អែកតាមមូលដ្ឋានខាងក្រោមនេះ(មាត្រាដដែល កថាខណ្ឌទី២)។
  - សហព័ន្ធនីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែករៀងៗខ្លួន (កថាខណ្ឌទី២ ចំណុច ក)
  - ជាគោលការណ៍ សហព័ន្ធនីមួយៗត្រូវទទួលបាន១ភាគ២នៃទ្រព្យសម្បត្តិរួម (កថាខណ្ឌទី២ ចំណុច ខ វាក្យខណ្ឌទី១)

# ទ្រព្យសម្បត្តិរួម និង ទ្រព្យសម្បត្តិដោយឡែក

- ជាគោលការណ៍ ទ្រព្យសម្បត្តិដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួម (ក្រមរដ្ឋប្បវេណីមាត្រា ៩៧៣)។
- ទ្រព្យសម្បត្តិដែលមិនមែនជាទ្រព្យសម្បត្តិរួម = ទ្រព្យសម្បត្តិដោយឡែក (ក្រមរដ្ឋប្បវេណីមាត្រា ៩៧២)
  - ទ្រព្យសម្បត្តិដែលសហព័ន្ធនីមួយៗមានកម្មសិទ្ធិ នៅមុនពេលរៀបអាពាហ៍ពិពាហ៍(មាត្រាដដែល ចំណុច ក)
  - ទ្រព្យសម្បត្តិដែលសហព័ន្ធម្ខាងទទួលបានដោយប្រទានកម្ម ឬ សន្តតិកម្ម នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ (មាត្រាដដែល ចំណុច ខ)
  - ទ្រព្យសម្បត្តិដែលទទួលបានពីកម្មវត្ថុនៃទ្រព្យសម្បត្តិទាំងនេះ(មាត្រាដដែល ចំណុច គ)

# ការបែងចែកទ្រព្យសម្បត្តិ

ចំពោះទ្រព្យសម្បត្តិដែលបានបង្កើតក្រោយពេលអាពាហ៍ពិពាហ៍ នឹងបែងចែកដោយស្មើភាពគ្នាតាមភាពជាក់ស្តែង ដោយធ្វើការពិចារណាលើកម្រិតនៃការផ្តល់ភាគទានផ្នែកសេដ្ឋកិច្ចរបស់ប្តីប្រពន្ធ ។

នៅក្នុងក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន មិនមានមាត្រាដែលចែងនូវភាគនៃការបែងចែកនោះឲ្យបានលម្អិតទេ។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង ប្រសិនបើគ្មានស្ថានភាពពិសេសទេ គេនឹងវាយតម្លៃនូវកម្រិតនៃការផ្តល់ភាគទានរបស់ភាគីទាំងសងខាងមានភាពស្មើគ្នា។ នៅប្រទេសកម្ពុជា ជាគោលការណ៍ សហព័ន្ធនីមួយៗទទួលយក១ភាគ២នៃទ្រព្យសម្បត្តិរួម ផ្អែកតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី( ក្រមរដ្ឋប្បវេណីមាត្រា ៩៨០ កថាខណ្ឌទី២ ចំណុច ខ វាក្យខណ្ឌទី១ )។

# ការបែងចែកទ្រព្យសម្បត្តិ

ក្នុងករណីប្រពន្ធ គឺជាស្ត្រីមេផ្ទះ ហើយរស់នៅដោយផ្អែកលើប្រាក់ចំណូលរបស់ប្តីជាគោល និងបានបង្កបង្កើនទ្រព្យសម្បត្តិ តើកម្រិតនៃការផ្តល់ភាគទានរបស់ប្រពន្ធនឹងត្រូវវាយតម្លៃដោយរបៀបណា ?

ចំពោះការអនុវត្តនៅប្រទេសជប៉ុន គេបានវាយតម្លៃថាកម្រិតនៃការផ្តល់ភាគទានតាមរយៈការងារគេហកិច្ចរបស់ប្រពន្ធស្មើគ្នានឹងកម្រិតនៃការផ្តល់ភាគទានតាមរយៈការធ្វើការរបស់ប្តី។ នៅប្រទេសកម្ពុជា ការងារគេហកិច្ច និង ការងារដែលធ្វើក្រៅផ្ទះ មានតម្លៃស្មើគ្នា (ក្រមរដ្ឋប្បវេណីមាត្រា ៩៨០ កថាខណ្ឌទី៣)។

# ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិ

- ទ្រព្យសម្បត្តិដែលប្តីប្រពន្ធបានសហការគ្នាបង្កបង្កើនបង្កើតឡើងក្រោយអាពាហ៍ពិពាហ៍ នឹងក្លាយជាកម្មវត្ថុនៃការបែងចែក។ ទោះបីជាមិនមានឈ្មោះរួមគ្នាលើទ្រព្យសម្បត្តិនោះក៏មិនអីដែរ។
  (ឧទា) ទោះបីជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបានដោយសហការគ្នា បានដាក់ឈ្មោះប្តីក៏ដោយ ក៏នឹងក្លាយជាកម្មវត្ថុនៃការបែងចែកដែរ។
- ទ្រព្យសម្បត្តិដោយឡែក(ក្រមរដ្ឋប្បវេណីមាត្រា៩៧២) nនឹងមិនក្លាយជាកម្មវត្ថុនៃការបែងចែកទេ។

# អំពីកាតព្វកិច្ច

- កាតព្វកិច្ចដែលបានកើតមានដោយសារតែការបង្កបង្កើនទ្រព្យសម្បត្តិរួមប្តីប្រពន្ធ ត្រូវបានគិតថាជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិ។

(ឧទា)

ករណីដែលបានខ្ចីប្រាក់ដើម្បីយកមកទិញអចលនវត្ថុដែលជាទ្រព្យសម្បត្តិរួមប្តីប្រពន្ធ

# ឧទាហរណ៍

X



ទ្រព្យសម្បត្តិរួមបានដាក់ឈ្មោះរបស់ x

ទ្រព្យសម្បត្តិរួមជាអចលនវត្ថុដែលបានដាក់ឈ្មោះ x តែម្នាក់ឯង ៣០ម៉ឺនដុល្លារ

បន្ទុកនៃកាតព្វកិច្ចដែលបានដាក់ឈ្មោះ x

ប្រាក់កម្ចីដើម្បីយកមកទិញអចលនវត្ថុ ១០ម៉ឺនដុល្លារ

Y



ទ្រព្យសម្បត្តិរួមដែលបានដាក់ឈ្មោះរបស់ Y

ប្រាក់បញ្ញើ ១០ម៉ឺនដុល្លារ

# ឧទាហរណ៍

X



- ចំនួនទឹកប្រាក់សរុបនៃទ្រព្យសម្បត្តិរួម (៣០ម៉ឺនដុល្លារ-១០ម៉ឺនដុល្លារ)+១០ម៉ឺនដុល្លារ=៣០ម៉ឺនដុល្លារ

- ចំនួនទឹកប្រាក់ដែលសហព័ន្ធនីមួយៗទទួលបាន ៣០ម៉ឺនដុល្លារ/២=១៥ម៉ឺនដុល្លារ

Y



- ចំនួនទឹកប្រាក់ដែល Y បានមិនទាន់គ្រប់ (=ចំនួនទឹកប្រាក់នៃការបែងចែករបស់ X) ១៥ម៉ឺនដុល្លារ-១០ម៉ឺនដុល្លារ=៥ម៉ឺនដុល្លារ

X ចែក៥ម៉ឺនដុល្លារឲ្យទៅ Y ។

# អ្នកមានអំណាចមេឃ

# ការកំណត់អ្នកមានអំណាចមេបា

នៅពេលលែងលះគ្នា ត្រូវកំណត់អំពីអ្នកមានអំណាចមេបាតាមការពិភាក្សារបស់ឪពុកម្ដាយ (ក្រមរដ្ឋប្បវេណីមាត្រា ១០៣៧ កថាខណ្ឌទី១)។ បើមិនអាចកំណត់តាមការពិភាក្សាបានទេ តុលាការនឹងកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូន(មាត្រាដដែល កថាខណ្ឌទី៣)។

តុលាការនឹងពិចារណាអំពីយោបល់របស់កូន ដោយថ្លឹងថ្លែងសមស្របទៅតាមអាយុ និង សភាពចាស់ទុំរបស់កូននោះ(ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា២២ កថាខណ្ឌទី៤)។

# ការកំណត់អ្នកមានអំណាចមេបា

ត្រូវពិចារណាអំពីសុខុមាលភាពរបស់កូនជាចម្បង ទាក់ទងនឹងថាតើឪពុក ឬ ម្ដាយនឹងក្លាយជាអ្នកមានអំណាចមេបា។

ប៉ុន្តែ មិនមានមូលដ្ឋានជាទូទៅណាមួយឡើយ ក្រៅពីការធ្វើការសម្រេចសេចក្ដីជារួមដោយពិចារណាលើស្ថានភាពនានាទេ។

# ធាតុដែលត្រូវយកមកពិចារណា

- ស្ថានភាពខាងឪពុកម្តាយ
  - សមត្ថភាពនៃការថែទាំ(អាយុ អត្តចរិត ការអប់រំ ស្ថានភាពសុខភាព)
  - បរិស្ថានគ្រួសារផ្នែកសតិអារម្មណ៍ និង ផ្នែកសេដ្ឋកិច្ច(បរិស្ថាននៃទ្រព្យសម្បត្តិ ប្រាក់ចំណូល មុខរបរ ការរស់នៅ ជីវភាព)
  - បរិស្ថាននៃលំនៅឋាន
  - បរិស្ថាននៃការអប់រំ
  - ស្ថានភាពនៃការថែទាំកន្លងមក
  - ទ្រព្យសម្បត្តិដែលមាននៅក្នុងផ្ទះ
  - ការជួយគាំទ្ររបស់សាច់ញាតិ

ជាដើម

# ធាតុដែលត្រូវយកមកពិចារណា

- ស្ថានភាពខាងកូន
  - អាយុ
  - ភេទ
  - ស្ថានភាពនៃការវិវត្តខាងផ្លូវកាយ និង ផ្លូវចិត្ត
  - ស្ថានភាពនៃការបន្សាំនឹងបរិស្ថាន
  - ការបន្សាំនឹងការផ្លាស់ប្តូរបរិយាកាស
  - ឆន្ទៈរបស់កូន
  - ទំនាក់ទំនងខាងអារម្មណ៍រវាងឪពុកម្តាយ និង សាច់ញាតិជាដើម

# ធាតុដែលត្រូវយកមកពិចារណា

- អ្នកថែទាំចម្បង

គេគិតថាគួរតែឲ្យអ្នកថែទាំចម្បងតាំងពីកុមារបានកើតបន្តការថែទាំ។ ប៉ុន្តែ នេះមិនមែនជាមូលដ្ឋានដាច់ខាតនោះទេ។ ទោះបីជាអ្នកថែទាំចម្បង ជាអ្នកមើលថែទាំក៏ដោយ បើសិនជាមានបញ្ហាទាក់ទងនឹងស្ថានភាពនៃការថែទាំ បរិស្ថានជីវភាព និងរបៀបនៃការថែទាំជាដើមនោះ ក៏អាចឲ្យឪពុក ឬ ម្ដាយម្ខាងទៀតជាអ្នកមានអំណាចមេបាដែរ។

- ការផ្លាស់ប្ដូរបរិស្ថានថែទាំ

បើសិនជាយកបុគ្គលដែលមិនមែនជាអ្នកថែទាំចម្បងជាអ្នកមានអំណាចមេបា នឹងធ្វើឲ្យមានការផ្លាស់ប្ដូរបរិស្ថានជីវភាពរបស់កូន។ ក្នុងករណីនេះ អាចនាំឲ្យស្ថានភាពផ្លូវចិត្តរបស់កូនមានភាពច្របូកច្របល់។ ដូចនេះ ក៏ចាំបាច់ត្រូវតែពិចារណាអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវក្នុងការផ្លាស់ប្ដូរបរិស្ថានថែទាំផងដែរ។

# ធាតុដែលត្រូវយកមកពិចារណា

- ឆន្ទៈរបស់កូន

ឆន្ទៈរបស់កូនចាំបាច់ត្រូវតែគោរព។ ប៉ុន្តែ ការក្តាប់យកឆន្ទៈរបស់កូន និង ការវាយតម្លៃលើឆន្ទៈរបស់កូន មិនមែនជារឿងងាយស្រួលនោះទេ។ ត្រូវតែរួមបញ្ចូលនូវអាយុរបស់កូន កម្រិតនៃការលូតលាស់ កម្រិតនៃសមត្ថភាពខាងភាសា និង ការបញ្ចេញមតិគោលជំហរនាពេលបច្ចុប្បន្នរបស់កូន និងប្រវត្តិនៃអប់រំរបស់កូន ជាដើម (យោងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា២២ កថាខណ្ឌទី៤)។

- មូលដ្ឋាននៃការមិនបែកចេញពីបងប្អូន

ជាទូទៅ គេយល់ថា មិនគួរបំបែកបងប្អូនតាំងពីពេលដែលចាប់កំណើតទេ។ ប៉ុន្តែ គេយល់ថា នេះមិនមែនជាមូលដ្ឋានដាច់ខាតនោះទេ គឺជាមូលដ្ឋានមួយនៃការពិចារណារួម។

# ធាតុដែលត្រូវយកមកពិចារណា

- ការអនុញ្ញាតអំពីការឲ្យចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន(ក្រមរដ្ឋប្បវេណីមាត្រា ១០៤០ កថាខណ្ឌទី១)

ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពីការចូលជួប និង ប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយម្ខាងទៀតនោះ អាចពិចារណានៅពេលកំណត់អំពីអ្នកមានអំណាចមេបា។

- ភាពខុសច្បាប់នៃការលួចយក

ក្នុងករណីដែលអ្នកថែទាំបានលួចយកកូនដោយមិនខ្វល់នឹងច្បាប់ ឬ វិធាននៅក្នុងសង្គម ហើយបានចាប់ផ្តើមថែទាំកូននោះ គេអាចវិនិច្ឆ័យថាបុគ្គលនោះមិនសាកសមធ្វើជាអ្នកមានអំណាចមេបាទេ។

# សោហ៊ុយអាពាហ៍ពិពាហ៍ និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន

# ការទទួលបន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍ និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន

- សោហ៊ុយអាពាហ៍ពិពាហ៍(ក្រមរដ្ឋប្បវេណីមាត្រា ៩៧១) តើត្រូវទទួលបន្ទុកសោហ៊ុយត្រឹមកម្រិតណា?
  - គេបានកំណត់ថា ចាំបាច់ត្រូវតែទទួលបន្ទុកសោហ៊ុយនូវកម្រិតជីវភាពដូចគ្នានឹងជីវភាពរបស់ខ្លួន(ឧទា៖ប្តី)មកធ្វើជាកម្រិតនៃការផ្គត់ផ្គង់ជីវភាពទៅឲ្យភាគីម្ខាងទៀត(ឧទា៖ប្រពន្ធ)
  - ពិចារណាទៅលើទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត ហើយធ្វើការកំណត់(មាត្រាដដែល)។

# ការទទួលបន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍ និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន

- សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន( ក្រមរដ្ឋប្បវេណី មាត្រា ១០៤០ )
  - ដូចគ្នានឹងសោហ៊ុយអាពាហ៍ពិពាហ៍ដែរ ចាំបាច់ត្រូវតែបង់នូវកម្រិតជីវភាពដូចគ្នានឹងជីវភាពរបស់ខ្លួន( ឧទាះឪពុក) ជាកម្រិតដែលត្រូវផ្តត់ផ្គង់ទៅឲ្យកូន។

  - តុលាការត្រូវតែកំណត់សោហ៊ុយចិញ្ចឹមបីបាច់កូនដោយគិតពិចារណាលើស្ថានភាពនៃជីវភាព និង ស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្តាយ (មាត្រាដដែល កថាខណ្ឌទី៦ )។

- នៅប្រទេសជប៉ុន គេកំណត់ដោយយកសោហ៊ុយអាពាហ៍ពិពាហ៍ រួមនឹងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន និងប្រាក់ចំណូលរបស់ឪពុកម្តាយ ធ្វើជាមូលដ្ឋាន។

# វិធីគណនាសោហ៊ុយអាពាហ៍ពិពាហ៍

1. សន្មតថាប្តីប្រពន្ធរួមរស់នៅជាមួយកូន ហើយគណនាប្រាក់ចំណូលមូលដ្ឋានសរុប

2. គណនាថ្លៃជីវភាពរៀងៗខ្លួនរបស់អ្នកមានករណីយកិច្ច និង អ្នកមានសិទ្ធិ ផ្អែកតាមប្រាក់ចំណូលមូលដ្ឋានក្នុងចំណុច1.

3. គណនាចំនួននៃគម្លាតរវាងប្រាក់ចំណូលមូលដ្ឋានរបស់អ្នកមានករណីយកិច្ច និង ថ្លៃជីវភាពរបស់អ្នកមានសិទ្ធិ។

# វិធីគណនាសោហ៊ុយអាពាហ៍ពិពាហ៍

- ប្រាក់ចំណូលមូលដ្ឋាន
  ចំនួនប្រាក់ដែលបានដកពន្ធ និង ការធានារ៉ាប់រងសង្គម ហើយនឹងថ្លៃជីវភាពពីចំនួនប្រាក់ចំណូល។ ក្នុងការអនុវត្ត ពុំមានការកំណត់ដោយឡែកឡើយ ហើយគេធ្វើការគណនាដោយយកភាគរយនៃចំនួនប្រាក់ចំណូលដែលបានកំណត់ ដោយផ្អែកតាមស្ថិតិ។
  - បុគ្គលិកក្រុមហ៊ុន ឬ មន្ត្រីរាជការ ៖ ប្រាក់ចំណូលតាមមុខងារ x 0.៣៤~0.៤២
  - អ្នកធ្វើអាជីវកម្មដោយខ្លួនឯង៖ ប្រាក់ចំណូលដែលបានកាត់ពន្ធ x 0.៤៧~0.៥២

- ការគណនាថ្លៃជីវភាព
  បើសិនជាមនុស្សពេញវ័យគេគិតថា១00 នៅក្នុងការអនុវត្តជាក់ស្តែង ថ្លៃជីវភាពរបស់កូននឹងត្រូវគណនាដូចតទៅ៖
  - កូនដែលមានអាយុ 0ឆ្នាំ~១៤ឆ្នាំ = ៥៥
  - កូនដែលមានអាយុ ១៥ឆ្នាំ~ ១៩ឆ្នាំ = ៩0

# ឧទាហរណ៍លម្អិត (សោហ៊ុយអាពាហ៍ពិពាហ៍)

X

Y កូន a (១៧ឆ្នាំ) កូន b (៥ឆ្នាំ)

ប្រាក់ចំណូលមូលដ្ឋាន
៥ ម៉ឺនដុល្លារ



ប្រាក់ចំណូលមូលដ្ឋាន ៣ ម៉ឺនដុល្លារ



# ឧទាហរណ៍លម្អិត
# (សោហ៊ុយអាពាហ៍ពិពាហ៍)




សន្មតថារួមរស់ជាមួយគ្នា ហើយធ្វើការគណនាប្រាក់ចំណូលមូលដ្ឋានសរុប។

៥ម៉ឺនដុល្លារ + ៣ម៉ឺនដុល្លា = ៨ម៉ឺនដុល្លារ

# ឧទាហរណ៍លម្អិត
# (សោហ៊ុយអាពាហ៍ពិពាហ៍)




ប្រាក់ចំណូលមូលដ្ឋានសរុប នឹងបែងចែកទៅឲ្យ
Y ផ្អែកតាមភាគរយនៃថ្លៃជីវភាព
៨ម៉ឺនដុល្លារ x ២៤៥/ ( ១០០+២៤៥ )
= ៥ម៉ឺន៦៨០០ដុល្លារ
ប្រាក់ចំណូលមូលដ្ឋានសរុប ៨ម៉ឺនដុល្លារ
X
Y
កូន a ( ១៧ឆ្នាំ ) កូន b ( ៥ឆ្នាំ )
ប្រាក់ចំណូលមូលដ្ឋាន
៥ ម៉ឺនដុល្លារ
ភាគរយនៃថ្លៃជីវភាព ១០០
ប្រាក់ចំណូលមូលដ្ឋាន ៣ ម៉ឺនដុល្លារ
ភាគរយនៃថ្លៃជីវភាព ២៤៥

# ឧទាហរណ៍លម្អិត
# (សោហ៊ុយអាពាហ៍ពិពាហ៍)

ប្រាក់ចំណូលមូលដ្ឋានសរុប ៨ ម៉ឺនដុល្លារ

X

Y កូន a (១៧ឆ្នាំ) កូន b (៥ឆ្នាំ)

ប្រាក់ចំណូលមូលដ្ឋាន ៥ ម៉ឺនដុល្លារ



ភាគរយនៃថ្លៃជីវភាព១០០

ប្រាក់ចំណូលមូលដ្ឋាន ៣ ម៉ឺនដុល្លារ



ភាគរយនៃថ្លៃជីវភាព២៤៥

ថ្លៃជីវភាព <u>៥ម៉ឺន៦៨០០ដុល្លារ</u>

ចំនួននៃសោហ៊ុយអាពាហ៍ពិពាហ៍ដែល X ត្រូវបង់ទៅឲ្យ Y ៖
ប្រាក់ចំណូលមូលដ្ឋានរបស់ Y (៣ម៉ឺនដុល្លារ) និង ចំនួនគម្លាត (២ម៉ឺន៦៨០០ដុល្លារ) នៃថ្លៃជីវភាព (៥ម៉ឺន៦៨០០ដុល្លារ)

# វិធីគណនាសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុក ដើម្បីគ្រប់គ្រងថែរក្សាកូន

1. គណនា<u>ប្រាក់ចំណូលមូលដ្ឋាន</u>របស់អ្នកមានករណីយកិច្ច

2. សន្មតថាអ្នកមានករណីយកិច្ច និង កូនរួមរស់នៅជាមួយគ្នា ហើយ គណនា<u>ថ្លៃជីវភាព</u>របស់កូន

3. គណនាចំនួនដែលអ្នកមានករណីយកិច្ចត្រូវទទួលបន្ទុក ដែលមាននៅក្នុងថ្លៃជីវភាពរបស់កូននៃចំណុច 2. ផ្អែកតាមភាគរយនៃប្រាក់ចំណូលមូលដ្ឋានរបស់អ្នកមានសិទ្ធិ និង អ្នកមានករណីយកិច្ច

# ឧទាហរណ៍លម្អិត
# (សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន)

X

ប្រាក់ចំណូលមូលដ្ឋាន ៥ ម៉ឺនដុល្លារ



Y　កូន a (១៧ឆ្នាំ)កូន b (៥ឆ្នាំ)

ប្រាក់ចំណូលមូលដ្ឋាន ៣ ម៉ឺនដុល្លារ



# ឧទាហរណ៍លម្អិត
# (សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន)




សន្មតថាអ្នកមានករណីយកិច្ច និង កូនរួមរស់នៅជាមួយគ្នា។

# ឧទាហរណ៍លម្អិត
# (សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន)

គណនាថ្លៃជីវភាពរបស់កូន។

X កូន a (១៧ឆ្នាំ)កូន b (៥ឆ្នាំ)

ប្រាក់ចំណូលមូលដ្ឋាន ៥ម៉ឺនដុល្លារ



ភាគរយនៃថ្លៃជីវភាព
១០០



៩០



៥៥

Y

ប្រាក់ចំណូលមូលដ្ឋាន ៣ម៉ឺនដុល្លារ



# ឧទាហរណ៍លម្អិត
# (សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន)

គណនាថ្លៃជីវភាពរបស់កូន។

X　កូន a (១៧ឆ្នាំ)កូន b (៥ឆ្នាំ)　　　　Y

ប្រាក់ចំណូលមូលដ្ឋាន៥មុឺនដុល្លារ




ប្រាក់ចំណូលមូលដ្ឋាន៣មុឺនដុល្លារ



៥មុឺនដុល្លារ x (៩០+៥៥)/(១០០+៩០+៥៥)=២មុឺន៩៥០០ដុល្លារ

# ឧទាហរណ៍លម្អិត
# (សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន)




គណនាចំនួនដែល X ត្រូវទទួលបន្ទុកយោងតាមភាគរយនៃប្រាក់ចំណូលមូលដ្ឋានរបស់ X និង Y។

២ម៉ឺន៩៥០០ដុល្លារ x ៥ម៉ឺនដុល្លារ / (៥ម៉ឺនដុល្លារ + ៣ម៉ឺនដុល្លារ) = ១ម៉ឺន៨៤០០ដុល្លារ

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!